# តើអ្នកដឹងឬទេ?

## ការរំលោភបំពានផ្លូវភេទលើកុមារគឺជាបញ្ហាសកល

ការរំលោភបំពានផ្លូវភេទលើកុមារកើតមានឡើងនៅគ្រប់ប្រទេសក្នុងពិភពលោក។ ទោះបីនៅក្នុងសហគមន៍របស់យើងមិនអាចថារួចផុតពីការរំលោភបំពានផ្លូវភេទលើកុមារនៅឡើយ។ ភាគច្រើនជនបំពារបំពានផ្លូវភេទលើកុមារអាចជាមនុស្សនៅក្នុងសហគមន៍។

## ជនរងគ្រោះពីការរំលោភបំពានផ្លូវភេទអាចជាក្មេងស្រី និងក្មេងប្រុស

ទាំងក្មេងស្រី និងក្មេងប្រុសអាចក្លាយជាជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទ។ កុមារភេទទី៣ (Third gender children) ឬកុមារដែលលេង/សំដែងសិចស៊ីអាចកើតមានហានិភ័យ។ កុមារពិការ (គ្រប់ប្រភេទនៃពិការភាព) ក៏អាចកើតមានហានិភ័យដែរ។ ការរំលោភបំពានផ្លូវភេទអាចកើតមានឡើងចំពោះកុមារគ្រប់ពេលទោះជាស្ថិតក្នុងជិវភាពយ៉ាងណាក៏ដោយ។

## ជនបំពារបំពានជារឿយៗគឺជាជនដែលស្គាល់កុមារ

ជនបំពារបំពានផ្លូវភេទលើកុមារជារឿយៗជាសមាជិកនៃគ្រួសារ សហគមន៍ ឬជនណាម្នាក់ដែលកុមារជឿជាក់។

## ជនបំពារបំពានអាចជាមិត្តភក្តិជនរងគ្រោះ និងគ្រួសាររបស់ពួកគេ

ជនបំពារបំពានជារឿយៗកសាងមិត្តភាពជាមួយជនរងគ្រោះ និងគ្រួសាររបស់ពួកគេគឺជាវិធីដែលពួកគេលាក់បាំងការបំពារបំពានរបស់ពួកគេ។

## ការបំពារបំពានផ្លូវភេទលើកុមារអាចកើតមានឡើងក្នុងបរិបទទេសចរណ៍

មានជនបរទេសមួយចំនួនតូចយកការធ្វើដំណើរជាឱកាសសម្រាប់រួមភេទជាមួយកុមារ។ ការធ្វើដំណើររបស់ជនល្មើសផ្លូវភេទលើកុមារគឺជាអ្នកទេសចរណ៍, អ្នកធ្វើដំណើរ, និវេសនជនបរទេសដែលប្រព្រឹត្តការរំលោភបំពានផ្លូវភេទលើកុមារនៅក្នុងប្រទេស ឬក្នុងបណ្តាប្រទេសដែលពួកគេកំពុងទស្សនា ឬកំពុងស្នាក់នៅ

## កុមារជារឿយៗកុមារមិនប្រាប់មនុស្សធំអំពីការរំពារបំពាន

ដោយហេតុផលជាច្រើន កុមារតែងតែមិនសូវនិយាយប្រាប់អំពីការបំពារបំពាន។ ដូច្នេះត្រូវសម្លឹងរកសញ្ញាជាជាងរងចាំកុមារមករាយការណ៍ប្រាប់។

## កុមារទាំងអស់មានសិទ្ធិទទួលបានការការពារ

កុមារទាំងអស់នៅលើពិភពលោកមានសិទ្ធិទទួលបានការការពារពីគ្រប់ទម្រង់នៃការរំលោភបំពាន។ ចំពោះមនុស្សធំ កិច្ចការទាំងអស់នេះគឺជាការត្រូវទទួលខុសត្រូវរបស់យើងដើម្បីការពារកុមារពីការធ្វើបាប។ កុមារមិនត្រូវទទួលការស្តីបន្ទោសចំពោះការរំលោភឡើយ។